ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធ

ព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ប្រកាសព័ត៌មាន លេខ ១៤ (ខែ មេសា ឆ្នាំ ២០១៥)

ស្របតាមផែនការមេរបស់គម្រោង FMIS ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនឹងប្រព្រឹត្តទៅនៅខែកក្កដា ឆ្នាំ២០១៥ ខាងមុខ។ ស្ថិតក្នុងស្ថានភាពនេះ ក្រុមការងាររួម គ្រោងនឹងរៀបចំបទបង្ហាញស្តីអំពីវឌ្ឍនភាពរបស់គម្រោង និងការបង្ហាញអំពីការប្រតិបត្តិផ្ទាល់របស់ប្រព័ន្ធ People Soft ដោយលើកយកការងារប្រចាំថ្ងៃមកអនុវត្តនូវក្នុងប្រព័ន្ធផ្ទាល់ សម្រាប់បង្ហាញជូនដល់ឯកឧត្តមរដ្ឋមន្ត្រី ដោយមានការចូលរួមពីថ្នាក់ដឹកនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធមកពីអគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធទាំងអស់ ឱ្យយល់អំពីលំហូការងាររបស់ប្រព័ន្ធជាមួយនឹងលំហូការងារប្រចាំថ្ងៃ។ ដោយឡែកអគ្គនាយកដ្ឋាន នាយកដ្ឋានពាក់ព័ន្ធបានបញ្ជូនចំនួនមន្ត្រី និងឈ្មោះមន្ត្រីដែលត្រូវប្រើប្រាស់ប្រព័ន្ធ FMISរួចរាល់ហើយ ប៉ុន្តែក្រុមការងារកំពុងពិភាក្សាជាមួយទីប្រឹក្សាគម្រោងដើម្បីរៀបចំចំនួនមន្ត្រី និងឈ្មោះមន្ត្រីឱ្យស្របទៅតាមការងារជាក់ស្តែងប្រចាំថ្ងៃជាមួយនឹងការប្រើប្រាស់ផ្ទាល់លើប្រព័ន្ធ FMIS មុននឹងបញ្ជូនឱ្យថ្នាក់លើធ្វើការសម្រេចជាក្រោយ។

ក្រុមការងារ FMWG បានបញ្ចប់ធ្វើការសាកល្បងការប្រើប្រាស់ប្រព័ន្ធ (System Integration Test) ទៅលើប្រព័ន្ធនេះដោយផ្អែកតាម Test Case និង Test Script ដើម្បីស្វែងរកកំហុសឆ្គងនានា និងកែសម្រួលមុនពេលដាក់ប្រព័ន្ធឱ្យប្រើប្រាស់ជាផ្លូវការរួចរាល់ហើយ ហើយរាល់កំហុសឆ្គងនានាក្រុមការងារ FMWGបានបញ្ជូនឱ្យក្រុមហ៊ុនផ្គត់ផ្គង់ធ្វើការកែតម្រូវមុនពេលការសាកល្បងការប្រើប្រាស់ប្រព័ន្ធលើកទីពីរមកដល់។ ក្រុមការងារ FMWG គ្រោងនឹងចាប់ផ្តើមការសាងល្បងស៊ីជម្រៅទៅលើការប្រើប្រាស់ប្រព័ន្ធ (System Integration Test) ដោយមានការចូលរួមពីអគ្គនាយកដ្ឋាន-នាយកដ្ឋានពាក់ព័ន្ធ ( User Acceptance Test) ដើម្បីស្វែងកំហុសណាមួយកើតឡើងកំឡុងពេលប្រព័ន្ធធ្វើប្រតិបត្តការ។ ដំណាក់កាលនេះគឺជារយៈពេលមួយដែលតម្រូវឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមដោយខាន់មិនបាន ពីព្រោះមន្ត្រីទាំងអស់នោះយល់ដឹងអំពីនីតិវិធីការងារប្រចាំថ្ងៃរបស់ខ្លួន ហើយការងារទាំងអស់នោះនឹងយកមកអនុវត្តនៅក្នុងប្រព័ន្ធផ្ទាល់ ដែលជាបច្ច័យមួយអាចឱ្យយើងស្វែងរកកំហុសណាមួយមុខពេលដែលប្រព័ន្ធដាក់ឱ្យដំណើរការជាផ្លូវការ។ ចំណែកការទាញយកទិន្នន័យជាក់ស្តែងពីប្រព័ន្ធនានា សម្រាប់មុខងារសៀវភៅធំ (General Ledger) និងការងារពាក់ព័ន្ធនឹងការធ្វើសន្ទានកម្មជាមួយប្រព័ន្ធ ASYCUDA ប្រព័ន្ធ DMFAS ប្រព័ន្ធ Payroll និងប្រព័ន្ធធនាគារជាតិ ក្រុមការងារគ្រោងនឹងបញ្ចប់នាពេលខាងមុខ។

ការទំនាក់ទំនងផ្សព្វផ្សាយផ្ទាល់ តាមគេហទំព័រ និងកិច្ចប្រជុំផ្សេង រួមទាំងព្រឹត្តិការនានា ក្រុមការងារគ្រប់គ្រងការផ្លាស់ប្តូរនៅតែបន្តអនុវត្តការផ្សព្វផ្សាយអំពីវឌ្ឍនភាពធ្វើយ៉ាងណាឱ្យអ្នកពាក់ព័ន្ធទាំងអស់យល់ឱ្យកាន់តែច្បាស់អំពីគម្រោង FMIS។ ក្រុមការងារគ្រប់គ្រងការផ្លាស់ប្តូរក៏បានចូលរួមក្នុងការរៀបចំចំនួនមន្ត្រី និងឈ្មោះមន្ត្រីសម្រាប់ប្រើប្រាស់ប្រព័ន្ធ ដើម្បីទប់ស្កាត់ផលប៉ះពាល់ទៅលើគម្រោង ធ្វើយ៉ាងណាឱ្យការប៉ះពាល់ស្ថិតក្នុងកម្រិតអប្បបរមា។

ក្រុមហ៊ុន ផ្គត់ផ្គង់កំពុងផ្តល់វគ្គបណ្តុះបណ្តាលទាក់ទងនឹងកម្មវិធី PeopleSoft ( GL & BA Administrator) ដើម្បីពង្រឹងសមត្ថភាពសមាជិកក្រុមការងារទាក់ទងនឹងមុខងារសំខាន់ទាំង៦របស់ប្រព័ន្ធ។ ក្រុមការងារហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍កំពុងសិក្សាលម្អិតបន្ថែមទៅលើទីតាំងសំខាន់សម្រាប់តម្លើងប្រព័ន្ធបណ្តាញ Network ទៅតាមទីតាំងដែលបានកំណត់ទុក និង កំពុងសិក្សាអំពីការទប់ស្កាត់ហានិភ័យដែលអាចកើតឡើងដោយយថាហេតុទៅមជ្ឈមណ្ឌលទិន្នន័យមេ (Data Center)។

***សូមក្រុមការងារ FMWGទាំងអស់ ចូលរួមឱ្យបានសកម្មទាក់ទងនឹងសកម្មភាពការងារនានារបស់គម្រោង ជាពិសេសចូលរួមការធ្វើតេស្តទៅលើប្រព័ន្ធក្នុងលក្ខណៈកម្រិតខ្ពស់ ដើម្បីឱ្យប្រព័ន្ធមានភាពត្រឹមត្រូវស្របតាមការងារប្រើប្រាស់ប្រចាំថ្ងៃ នឹងដើម្បីឈានទៅរកការប្រើប្រាស់លក្ខណៈជាតិនាពេលខាងមុខ។***

សម្រាប់ព័ត៌មានបន្ថែមផ្សេងៗ សូមចូលទៅកាន់គេហទំព័រ ឬទំនាក់ទំនងតាមអ៊ីមែល ឬទូរស័ព្ទដូចខាងក្រោម÷

គេហទំព័រ÷ http://fmis.mef.gov.kh អ៊ីមែល÷ fmis.info@mef.gov.kh ទូរស័ព្ទទំនាក់ទំនង÷ 023 430 063